# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)

# គម្រោងបញ្ចប់ផែនការ

## កំណែលើកទី ៦

## ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៥

**សេចក្តីសង្ខេប** .......... 2
I. **សេចក្តីផ្តើម** .......... 3
II. **វិធានការដែលអាចជួយបញ្ចប់ផែនការបានឆាប់រហ័ស** .......... 9
III. **ផែនការបញ្ចប់ការស៊ើបអង្កេត** .......... 11
IV. **ផែនការបញ្ចប់សវនាការ** .......... 15
ក. សំណុំរឿង០០២/០២ .......... 16
ខ. បទចោទដែលនៅសេសសល់/ការចោទប្រកាន់តាមអង្គហេតុក្នុងសំណុំរឿង០០២ .......... 19
គ. សំណុំរឿង០០៣ និង សំណុំរឿង០០៤ .......... 19
V. **ផែនការបញ្ចប់បណ្តឹងសាទុក្ខ** .......... 19
ក. សំណុំរឿង០០២/០១ .......... 20
ខ. សំណុំរឿង០០២/០២ .......... 23
VI. **សេចក្តីសន្និដ្ឋាន** .......... 24

ឧបសម្ព័ន្ធ ៖ តារាងកំណត់ពេលវេលាតាមការគ្រោងទុកសម្រាប់ការបញ្ចប់ផែនការ ដែលរួមមានគ្រោងការសំខាន់ៗ។

01739843

## សេចក្តីសង្ខេប

គម្រោងបញ្ចប់ផែនការសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អង្គជំនុំជម្រះ”) ត្រូវបានរៀបចំឡើងនៅខែ មីនា ឆ្នាំ ២០១៤ ដោយឆ្លងកាត់ការពិគ្រោះពិភាក្សាយោបល់ពីសំណាក់ការិយាល័យរដ្ឋបាល ជាមួយនឹងចៅក្រមនៃអង្គជំនុំជម្រះផ្សេងៗ សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញា ទាក់ទិននឹងការទទួលខុសត្រូវរបស់ពួកគាត់។ នេះគឺជាការធ្វើបច្ចុប្បន្នភាពប្រចាំត្រីមាសទី ៦ នៃគម្រោងបញ្ចប់ផែនការនេះដែលផុតនៅថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៥។

ក្នុងត្រីមាសចុងក្រោយនេះ អង្គជំនុំជម្រះតុលាការកំពូលបានចាប់ផ្តើមដំណើរការសវនាការបឋមលើបណ្តឹងសាទុក្ខនៅក្នុងសំណុំរឿង ០០២/០១។ គ្រោងការបន្ថែមមួយដែលបានគ្រោងសម្រាប់ឆ្នាំ ២០១៥ ត្រូវបានសម្រេច ដោយបានបញ្ចូលការដាក់ចម្លើយតបទៅនឹងបណ្តឹងសាទុក្ខលើអង្គសេចក្តីយ៉ាងហោចណាស់ជាភាសាផ្លូវការចំនួនពីររបស់អង្គជំនុំជម្រះ។ សំណើសុំដាក់ភ័ស្តុតាងបន្ថែមដែលបានស្នើឡើងដោយ នួន ជា បានធ្វើឲ្យមានភាពស្មុគស្មាញជារួមដល់កិច្ចដំណើរការនីតិវិធី។ ដោយសារនាពេលនេះ ការដាក់សារណាបណ្តឹងសាទុក្ខលើអង្គសេចក្តីបានចប់សព្វគ្រប់ នាពេលនេះ អង្គជំនុំជម្រះតុលាការកំពូលអាចវាយតម្លៃទៅលើវិសាលភាពពេញលេញនៃបណ្តឹងសាទុក្ខដែលកំពុងរង់ចាំការសម្រេច ដែលមានភាពស្មុគស្មាញជាងអ្វីដែលបានគិតទុកពីដំបូង។ កត្តាទាំងនេះតម្រូវឲ្យមានការកែសម្រួលថិរវេលាដែលបានគ្រោងទុកសម្រាប់ការចេញសាលដីកាលើបណ្តឹងសាទុក្ខរយៈពេលបីខែ។

នៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការក្នុងសំណុំរឿង ០០២/០២ សវនាការលើភ័ស្តុតាងបានបន្ត ដោយបានបញ្ចប់ប្រធានបទទី ២ ស្តីពីការដ្ឋានការងារជាក់លាក់ចំនួន ៣ កន្លែង។ បច្ចុប្បន្ន អង្គជំនុំជម្រះសាលាដំបូងកំពុងដំណើរការសវនាការពិនិត្យភស្តុតាងលើប្រធានបទទី ៣ ស្តីពីការប្រព្រឹត្តិចំពោះជនជាតិចាម និងជនជាតិវៀតណាម ដែលរួមមាន បទចោទពីអំពើប្រល័យពូជសាសន៍ក្នុងចំណោមឧក្រិដ្ឋកម្មផ្សេងៗទៀត។ មានការរីកចម្រើនជាច្រើនដែរក្នុងកិច្ចស៊ើបសួរនៅក្នុងសំណុំរឿង ០០៣ និង ០០៤។

ការពិពណ៌នាអំពីពីគម្រោងបញ្ចប់ផែនការនេះត្រូវបានធ្វើបច្ចុប្បន្នភាព ក្នុងគោលបំណងដើម្បីឆ្លុះបញ្ចាំងអំពីស្ថានភាពនៃដំណើរការនីតិវិធីតុលាការគិតត្រឹមថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៥។

01739844

## I. សេចក្តីផ្តើម

១ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អង្គជំនុំជម្រះវិសាមញ្ញ") បានចាប់ផ្តើមដំណើរការរបស់ខ្លួននៅខែកុម្ភៈ ឆ្នាំ២០០៦ និងបានដំណើរពេញលេញបន្ទាប់ពីការអនុម័តវិធានផ្ទៃក្នុងនៅក្នុងខែមិថុនា ឆ្នាំ២០០៧។ អណត្តិរបស់អង្គជំនុំជម្រះវិសាមញ្ញ គឺដើម្បីកាត់សេចក្តី "មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី ១៧ ខែ មេសា ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ១៩៧៩"[1]។ នៅក្នុងរបាយការណ៍មួយ ដែលបានដាក់ជូនមហាសន្និបាតអង្គការសហប្រជាជាតិនៅខែ មីនា ឆ្នាំ ២០០៣ អគ្គលេខាធិការ ដំបូងឡើយបានបង្ហាញថា អាណត្តិរបស់អង្គជំនុំជម្រះវិសាមញ្ញ មានរយៈពេលបីឆ្នាំ ដើម្បីបញ្ចប់ការជំនុំជម្រះនៅអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលទាំងអស់ "នៅពេលដែលការិយាល័យរបស់សហព្រះរាជអាជ្ញា បានចាប់ផ្តើមប្រតិបត្តិការរបស់ខ្លួន"[2]។ តារាងកំណត់ពេលវេលាត្រូវបានកែប្រែចាប់តាំងពីពេលនោះមក ហើយអគ្គលេខាធិការបានជូនដំណឹងជាផ្លូវការដល់មហាសន្និបាតអង្គការសហប្រជាជាតិនៅខែ តុលា ឆ្នាំ ២០១៣ ថា តារាងកំណត់ពេលវេលារបស់អង្គជំនុំជម្រះវិសាមញ្ញ "មានគម្រោងសកម្មភាពតុលាការរហូតដល់ឆ្នាំ២០១៨ និងអាចបន្តហួសពីពេលវេលាកំណត់នេះទៅទៀត"[3]។

២ គម្រោងបញ្ចប់ផែនការនេះបានបរិយាយយ៉ាងលម្អិតដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងបរិបទនៃសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ A/RES/68/247B ដែលក្នុងចំណោមបញ្ហាផ្សេងៗទៀត បានកំណត់អាណត្តិរបស់អង្គជំនុំជម្រះវិសាមញ្ញឲ្យរៀបចំយុទ្ធសាស្ត្របញ្ចប់ ដោយមាន

---

[1] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។

[2] របាយការណ៍របស់អគ្គលេខាធិការស្តីពីការជំនុំជម្រះខ្មែរក្រហម ឯកសារ A/57/769 កថាខណ្ឌ៥៦។

[3] សំណើសុំឧបត្ថមធនសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឯកសារ A/68/532 កថាខណ្ឌ៣៨។

ផែនទីបង្ហាញផ្លូវច្បាស់លាស់មួយ[4]។ ឯកសារនេះធ្វើឡើងដោយអង្គជំនុំជម្រះវិសាមញ្ញដោយមានការពិគ្រោះយោបល់តាមរយៈការិយាល័យរដ្ឋបាលជាមួយចៅក្រមអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញាអំពីការទទួលខុសត្រូវរបស់ពួកគេ។ អង្គជំនុំជម្រះវិសាមញ្ញគិតទុកជាមុនថានៅពេលខាងមុខខ្លួននឹងធ្វើបច្ចុប្បន្នភាពផែនការបញ្ចប់នេះរៀងរាល់ត្រីមាស។ ឯកសារនេះគឺជាកំណែលើកទី៦ ប្រចាំត្រីមាសនៃគម្រោងបញ្ចប់ផែនការ ហើយបានបញ្ចូលនូវការកែតម្រូវដែលចាំបាច់នានា ដោយផ្អែកលើការវិវត្តនៃដំណើរការនីតិវិធីតាមផ្លូវតុលាការដែលកំពុងប្រព្រឹត្តទៅក្នុងរវាងថ្ងៃទី ១ ខែ កក្កដា ដល់ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៥។

៣ ឯកសារនេះផ្តោតជាពិសេសលើការវិវត្តន៍នាពេលថ្មីៗនេះ នៅក្នុងសំណុំរឿងដែលនៅសេសសល់ទាំងបីដែលបច្ចុប្បន្នកំពុងស្ថិតនៅចំពោះមុខ អ.វ.ត.ក និងផ្តល់នូវព័ត៌មានអំពីប្រភេទនៃរឿងក្តី ព្រមទាំងស្ថានភាពនៃសំណុំរឿងទាំងនោះ ព្រមទាំងជំហាននានាដែលត្រូវបំពេញ មុនពេលកិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការទាក់ទិននឹងសំណុំរឿងកំពុងរង់ចាំបច្ចុប្បន្ននៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ បញ្ចប់ជាស្ថាពរតាមផ្លូវច្បាប់។ សហព្រះរាជអាជ្ញាបានថ្លែងជាសាធារណៈថា នឹងពុំមានសំណុំរឿងបន្ថែមទៀតទេបន្ទាប់ពីសំណុំរឿង ០០៣ និង ០០៤[5]។ ហេតុនេះ សំណុំរឿងដែលមាននាពេលនេះគឺជាសំណុំរឿងសរុបដែល អ.វ.ត.ក ត្រូវដោះស្រាយ។

---

[4] នៅក្នុងសេចក្តីសម្រេចដដែលនោះ មហាសន្និបាត អ.ស.ប បានស្នើឲ្យមាន "ការពិនិត្យយ៉ាងម៉ត់ចត់ទៅលើការផ្តល់ហិរញ្ញប្បទានសម្រាប់ អ.វ.ត.ក នៅពេលអនាគតសម្រាប់ឆ្នាំ ២០១៥ និងឆ្នាំខាងមុខទៀត"។ សូមមើលសេចក្តីសម្រេចលេខ A/RES/68/247B ដែលអនុម័តដោយមហាសន្និបាត អ.ស.ប នៅថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១៤។ "កម្មវត្ថុពិសេសនានាទាក់ទិននឹងថវិកាសម្រាប់កម្មវិធីរយៈពេល២ឆ្នាំម្តង ២០១៤-២០១៥" B, I, កថាខណ្ឌទី៨។

[5] សេចក្តីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី៖ អំពីការដាក់ជូននូវដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មីៗ ចំនួន ២ ចេញផ្សាយថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០០៩ (www.eccc.gov.kh/sites/default/files/media/ECCC_Act_Int_Co_Prosecutor_8_Sep_2009_(Eng).pdf)។ សេចក្តីថ្លែងការណ៍សាធារណៈដោយសហព្រះរាជអាជ្ញាទាក់ទិននឹងការស៊ើបអង្កេតក្នុងសំណុំរឿង ០០៣ ចេញផ្សាយថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ ២០១២ (www.eccc.gov.kh/sites/default/files/media/ECCC%20OCP%205%20June%202012%20En.pdf) និងសេចក្តីថ្លែងការណ៍ដោយសហព្រះរាជអាជ្ញាអន្តរជាតិទាក់ទិននឹងបន្ទុកការងាររបស់ អ.វ.ត.ក ចេញផ្សាយថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៤ (http://www.eccc.gov.kh/en/articles/statement-international-co-prosecutor-regarding-eccc-caseload)។

01739846

៤ មកដល់ពេលនេះអង្គជំនុំជម្រះបានបំបែកបទចោទនៅក្នុងសំណុំរឿង ០០២ ទៅជាសវនាការតូចៗ ចំនួនពីរ ។ អង្គជំនុំជម្រះសាលាដំបូងបានចេញសាលក្រមនៅក្នុងសវនាការដំណាក់កាលទីមួយ ដែល អង្គជំនុំជម្រះវិសាមញ្ញកំណត់ឈ្មោះ សំណុំរឿងថា សំណុំរឿង០០២/០១ នៅថ្ងៃទី ៧ ខែសីហា ឆ្នាំ ២០១៤ ប្រឆាំងនឹង នួន ជា និង ខៀវ សំផន។ ជនជាប់ចោទពីរនាក់ទៀតនៅក្នុងរឿងក្តី គឺ អៀង សារី និង អៀង ធីរិទ្ធ បានទទួលមរណភាពនៅថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣ និងថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៥ ហេតុនេះហើយ កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងពួកគេត្រូវបានរំលត់។ អង្គជំនុំជម្រះសាលា ដំបូងបានរកឃើញថា ខៀវ សំផន និង នួន ជា មានពិរុទ្ធភាពពីបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៧ និងត្រូវបាន ផ្តន្ទាទោសម្នាក់ៗឲ្យជាប់ពន្ធនាគារអស់មួយជីវិត។ ទាំង នួន ជា និង ខៀវ សំផន បានដាក់បណ្តឹង សាទុក្ខប្រឆាំងនឹងសាលក្រមសាលាដំបូងក្នុងសំណុំរឿង០០២/០១។ សហព្រះរាជអាជ្ញាក៏បានដាក់ បណ្តឹងសាទុក្ខកម្រិតត្រឹមតែស្នើសុំ សេចក្តីប្រកាសជាប្រយោជន៍ទៅលើការអនុវត្តទម្រង់ទូលាយ បំផុតនៃសហឧក្រិដ្ឋកម្មរួមដែលហៅថា JCE III ជាទម្រង់ទទួលខុសត្រូវមួយនៅចំពោះមុខអង្គជំនុំ ជម្រះវិសាមញ្ញ។

៥ ដំណើរការនីតិវិធីបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ កំពុងតែអនុវត្ត ដោយនៅពេលនេះ សារណា លើបណ្តឹងសាទុក្ខទាំងអស់ត្រូវបានដាក់ ទៅតាមការតម្រូវ ដោយយ៉ាងហោចណាស់ជាភាសាផ្លូវការ ចំនួនពីររបស់អង្គជំនុំជម្រះវិសាមញ្ញ។ អង្គជំនុំជម្រះតុលាការកំពូលបានដំណើរការសវនាការលើ បណ្តឹងសាទុក្ខលើកដំបូងរបស់ខ្លួននៅថ្ងៃទី ២ ទី ៣ និង ទី ៦ ខែ កក្កដា ឆ្នាំ ២០១៥ ហើយសវនាការ លើបណ្តឹងសាទុក្ខបន្ថែមទៀតត្រូវបានរំពឹងថានឹងដំណើរការក្នុងត្រីមាសទី ៤ ក្នុងឆ្នាំ ២០១៥។ ថិរវេលាដែលបានគ្រោងសម្រាប់ការចេញសាលដីកាលើបណ្តឹងសាទុក្ខនៅក្នុងសំណុំរឿង ០០២/០២ ត្រូវបានកែសម្រួលរយៈពេលបីខែ ដោយសារមានការវិវត្តន៍ច្រើននៅក្នុងកិច្ចដំណើរការនីតិវិធីលើ បណ្តឹងសាទុក្ខ ដូចបានពន្យល់បន្ថែមក្នុងជំពូក V ខាងក្រោម។

៦ ការជំនុំជម្រះទីពីរកំពុងដំណើរការក្នុងពេលបច្ចុប្បន្ននេះ ដែលអង្គជំនុំជម្រះវិសាមញ្ញដាក់ឈ្មោះថា សំណុំរឿង ០០២/០២ គឺផ្តោតលើជម្រើសតំណាងបទចោទមួយចំនួនដែលនៅសល់ប្រឆាំងនឹងជនជាប់ ចោទទាំងពីរនាក់។ បទចោទទាំងនោះរួមមាន៖ អំពើប្រល័យពូជសាសន៍លើក្រុមជាតិពន្ធុចាមនិង

វៀតណាម អាពាហ៍ពិពាហ៍ដោយបង្ខំ និងរំលោភសេពសន្ថវៈ ការប្រព្រឹត្តិលើពុទ្ធសាសនិក ការបោសសម្អាតផ្ទៃក្នុង និង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលចោទប្រកាន់ថាបានប្រព្រឹត្តនៅមន្ទីរសន្តិសុខចំនួន៤ ការដ្ឋានចំនួន៣ និង សហករណ៍មួយចំនួនជាក់លាក់។ សវនាការលើភស្តុតាងក្នុងសំណុំរឿង ០០២/០២ បានចាប់ផ្តើមនៅថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥។ នៅត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៥ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សក្ខីកម្មសាក្សីចំនួន ៤៦ នាក់ ដើមបណ្តឹងរដ្ឋប្បវេណី ៣១ នាក់ និងអ្នកជំនាញម្នាក់។ ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនត្រូវបានស្តាប់សក្ខីកម្មក្នុងអំឡុងពេលពេលសវនាការដែលរៀបចំជាក់លាក់សម្រាប់ការស្តាប់សក្ខីកម្មស្តីពីការឈឺចាប់របស់ដើមបណ្តឹងរដ្ឋប្បវេណីនៅតាមសហករណ៍ និងការដ្ឋាន។

៧ បច្ចុប្បន្ន សំណុំរឿង០០៣ និង ០០៤ កំពុងតែស្ថិតក្នុងដំណាក់កាលស៊ើបសួរនៅឡើយ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិកំពុងតែស៊ើបអង្កេតយ៉ាងសកម្មទៅលើសំណុំរឿងទាំងនេះ ដែលពាក់ព័ន្ធនឹងការចោទប្រកាន់ជនត្រូវចោទ ៣ នាក់ និង ជនសង្ស័យ ១ នាក់។ មានការបន្តរីកចម្រើនជាច្រើនទៅលើសំណុំរឿងទាំងពីរនេះ នៅក្នុងអំឡុងត្រីមាសទី ៣ ឆ្នាំ២០១៥។ នៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិនាពេលនោះគឺ ចៅក្រម Mark Harmon បានប្រកាសជាសាធារណៈថា គាត់បានលាលែងចេញពីតំណែងដោយសារមូលហេតុផ្ទាល់ខ្លួន។ នៅថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០១៥ ចៅក្រម Michael Bohlander ដែលពីមុនជា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ត្រូវបានតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជាធ្វើជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិថ្មី បន្ទាប់ពីមានការចាត់តាំងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ។

៨ បច្ចុប្បន្ន សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលទើបតែត្រូវបានតែងតាំងថ្មីកំពុងពិនិត្យលើស្ថានភាពក្នុងសំណុំរឿង រួមទាំងបណ្តឹងនានាដែលកំពុងរង់ចាំការសម្រេច បន្ទុកការងារនៅសេសសល់ដែលត្រូវបានគិតទុក និងថិរវេលាសម្រាប់បញ្ចប់ដែលបានគ្រោងទុកនៅក្នុងសំណុំរឿង ០០៣ និង ០០៤។ ការពិនិត្យនេះនឹងបន្តទៅដល់ត្រីមាសទី ៤ ក្នុងឆ្នាំ ២០១៥ ហើយការកែសម្រួលចំពោះថិរវេលាដែលបានគ្រោងទុក ចេញពីការពិនិត្យនេះ នឹងត្រូវដាក់បញ្ចូលនៅក្នុងផែនការបញ្ចប់បន្ទាប់។ ការគិតទុកជាមុននោះគឺថា សេចក្តីជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ អាចនឹងចេញនៅត្រីមាស

ទី ៤ ក្នុងឆ្នាំ ២០១៥ ហើយសេចក្តីសម្រេចមួយ ក្នុងទម្រង់ជាដីកាដំណោះស្រាយ ថាតើនឹងត្រូវចោទប្រកាន់ និងបញ្ជូនទៅជំនុំជម្រះ ឬយ៉ាងណានោះ នឹងចេញនៅត្រីមាសទី ៣ ឆ្នាំ២០១៦។

៩ តាមរយៈការវិវត្តន៍ក្នុងត្រីមាសចុងក្រោយនេះ គម្រោងបញ្ចប់ផែនការរបស់អង្គជំនុំជម្រះវិសាមញ្ញមានគ្រោងការសំខាន់ចំនួន១៣សម្រាប់សំណុំរឿងចំនួនបីដែលអង្គជំនុំជម្រះនានាបានទទួល។ គ្រោងការសំខាន់ដែលនៅសេសសល់នៅក្នុងសំណុំរឿង០០២[6] និង ការព្យាករណ៍ ដែលបន្តពាក់ព័ន្ធគឺ៖

(i) ការបញ្ចប់សវនាការលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ (ត្រឹមត្រីមាសទី៤ ឆ្នាំ ២០១៥)

(ii) ការចេញសាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២/០១ ប្រសិនបើមាន(ត្រីមាសទី ២ ឆ្នាំ ២០១៦)

(iii) ការបញ្ចប់សវនាការលើអង្គសេចក្តី ក្នុងសំណុំរឿង០០២/០២ (ត្រឹមត្រីមាសទីបី ឆ្នាំ២០១៦)

(iv) សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ក្នុងសំណុំរឿង០០២/០២ (ត្រីមាសទីបួន ឆ្នាំ២០១៦)

(v) ការចេញសាលក្រមនៅក្នុងសំណុំរឿង០០២/០២ (ត្រីមាសទីបី ឆ្នាំ២០១៧)

(vi) ពេលវេលាកំណត់នៃការដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ក្នុងសំណុំរឿង០០២/០២ (ត្រីមាសទីបួន ឆ្នាំ២០១៧) និង

(vii) ការចេញសាលក្រមនៅក្នុងសំណុំរឿង០០២/០២ ប្រសិនបើមាន (ត្រីមាសទីពីរ ឆ្នាំ២០១៩)

១០ នៅក្នុងសំណុំរឿង ០០៣ និង ០០៤ គ្រោងការដាច់ដោយឡែក ត្រូវបានកំណត់សម្រាប់ដំណាក់កាលស៊ើបអង្កេត ដែលនៅសេសសល់ ហើយក្នុងករណីមានការចោទប្រកាន់នោះ នឹងមានគ្រោងការបន្ថែម

[6] នៅក្នុងករណីដែលសំណុំរឿង០០២ ត្រូវបានបំបែកបន្ថែមទៀតតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះទៅលើវិសាលភាពនៃសំណុំរឿង០០២/០២ ដែលរំពឹងថានឹងចេញនៅខែ មេសា ឆ្នាំ ២០១៤ វានឹងតម្រូវឲ្យមានសំណុំរឿង០០២/០៣។

ទៀតសម្រាប់ដំណាក់កាលជំនុំជម្រះ និងបណ្ដឹងសាទុក្ខ[7]។ គ្រោងការសំខាន់សម្រាប់ដំណាក់កាលស៊ើបអង្កេតដែលបន្តនៅសេសសល់ ដែលអាចមានការកែសម្រួល ដោយសារតែការពិនិត្យដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលទើបតែងតាំងថ្មី កំពុងតែធ្វើនេះ គឺ៖

(viii) សេចក្ដីជូនដំណឹងអំពីការការបញ្ចប់កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ (ត្រីមាសទី៤ ឆ្នាំ២០១៥)

(ix) សេចក្ដីជូនដំណឹងអំពីការការបញ្ចប់កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៤(ត្រីមាសទី៤ និង/ឬត្រីមាសទី១ ឆ្នាំ២០១៦ អាស្រ័យទៅលើការបំបែកកិច្ចនីតិវិធីណាមួយ) ។

(x) ការចេញដីកាដំណោះស្រាយក្នុងសំណុំរឿង០០៣ ជាមួយនឹងសេចក្ដីសម្រេចថាតើបញ្ជូនរឿងទៅជម្រះ ឬក៏បញ្ចប់កិច្ចនីតិវិធី (ត្រីមាសទី៣ ឆ្នាំ២០១៦)។

(xi) ការចេញដីកាដំណោះស្រាយ(១ឬច្រើន) ក្នុងសំណុំរឿង០០៤ ជាមួយនឹងសេចក្ដីសម្រេចថាតើត្រូវបញ្ជូនរឿងទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធី(អាស្រ័យលើថាតើសំណុំរឿងនឹងត្រូវបំបែក ឬអត់ នៅត្រីមាស១ ទី៣ ឬទី៤ ឆ្នាំ២០១៦)។

(xii) សេចក្ដីសម្រេចដោយអង្គបុរេជំនុំជម្រះ លើបណ្ដឹងឧទ្ធរណ៍ណាមួយប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង០០៣ ថាតើត្រូវបញ្ជូនរឿងទៅជំនុំជម្រះឬបញ្ចប់កិច្ចនីតិវិធីក្នុងសំណុំរឿងនោះ (ត្រីមាសទីមួយ ឆ្នាំ២០១៧ សម្រាប់សំណុំរឿង០០៣ ។ និង

(xiii) សេចក្ដីសម្រេចដោយអង្គបុរេជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍ណាមួយប្រឆាំងនឹងដីកាដំណោះស្រាយមួយ(ឬច្រើន)ក្នុងសំណុំរឿង០០៤ ថាតើត្រូវបញ្ជូនរឿងទៅជំនុំជម្រះឬបញ្ចប់កិច្ចនីតិវិធីក្នុងសំណុំរឿងនោះ(ត្រីមាសទី២ ឆ្នាំ២០១៧)

---

[7] ដូចដែលកត់សម្គាល់ត្រង់កថាខណ្ឌទី៣៥ខាងក្រោម ដោយសាស្ថានភាពនៃកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ន នៅពេលនេះយើងមិនអាចព្យាករណ៍នូវចំណុចពេលវេលាជាក់លាក់ទាក់ទិននឹងគ្រោងការជំនុំជម្រះក្ដីបានឡើយ។ នៅក្នុងករណីដែលរឿងក្ដី០០៣ និង០០៤ ត្រូវបញ្ជូនទៅជំនុំជម្រះ គ្រោងការនៃសវនាការលើអង្គសេចក្ដីគឺអាចដូចទៅនឹងប្រការដែលមានចែងនៅក្នុងកថាខណ្ឌទី១២(iv) រហូតដល់ (viii) ខាងលើ ទាក់ទិននឹងសំណុំរឿង០០២/០២។

## II. វិធានការដែលអាចជួយបញ្ចប់ផែនការបានឆាប់រហ័ស

១១ ដំណើរការប្រកបដោយប្រសិទ្ធិភាពរបស់អង្គជំនុំជម្រះវិសាមញ្ញ កន្លងទៅត្រូវបានរំខានដោយអសន្តិសុខផ្នែកហិរញ្ញវត្ថុដែលចេះតែបន្តកើតមាន ដែលបណ្តាលឲ្យបុគ្គលិកចំនួនពីររូបបានបោះបង់ការងារក្នុងអំឡុងឆ្នាំ២០១៣ ព្រមទាំងបុគ្គលិកចេញចូលពីមុខតំណែងដោយមិនសមហេតុផល។ ការអនុម័តរបស់មហាសន្និបាតទៅលើឧបត្ថម្ភធនចំនួន ១៥,៥ លានដុល្លារសម្រាប់ភាគីអន្តរជាតិ នៃ អ.វ.ត.ក គឺជាវិធានការដ៏សំខាន់ដែលបានធ្វើឲ្យមានស្ថិរភាពដល់ស្ថានភាពថវិកាសម្រាប់ឆ្នាំ២០១៤ និងធ្វើឲ្យមានការផ្តោតមូលទៅលើការធ្វើឲ្យវិវត្តទៅមុខនៃអាណត្តិតុលាការ[8]។ នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥ មហាសន្និបាតអង្គការសហប្រជាជាតិ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនលេខ ៦៩/២៧៤ បានអនុញ្ញាតឲ្យអគ្គលេខាធិការសន្យាជាផ្លូវការក្នុងការផ្តល់ថវិកាចំនួន ១២.១ លានដុល្លារ ដើម្បីបន្ថែមទៅលើធនធានហិរញ្ញវត្ថុរបស់ ភាគីអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញសម្រាប់ឆ្នាំ២០១៥ ដែលនឹងផ្តល់នូវស្ថិរភាពប្រហាក់ប្រហែលគ្នានៅឆ្នាំខាងមុខជាមួយនឹងការផ្តល់វិភាគទានស្ម័គ្រចិត្ត និងការគាំទ្រពីប្រទេសផ្តល់ជំនួយ។ ដោយទទួលស្គាល់នូវដំណាក់កាលដែលមានបន្ទុកការងារខ្ពស់បំផុតនៅក្នុងកិច្ចការរបស់អង្គជំនុំជម្រះវិសាមញ្ញ និង ការពាក់ព័ន្ធទៅនឹងយកចិត្តទុកដាក់លើធនធាននោះ ក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗក៏បាន អនុម័តទៅលើគម្រោងថវិកាកែសម្រួលថ្មីសម្រាប់ឆ្នាំ២០១៥ដែលរួមបញ្ចូលនូវធនធានថ្មីៗទៅលើវិស័យសំខាន់ៗជាច្រើន។ទិដ្ឋភាពដ៏វិជ្ជមានមួយ គឺការបង្កើនវិភាគទានពីរាជរដ្ឋាភិបាលកម្ពុជា ដែល ចំណាយទៅលើប្រាក់ខែបុគ្គលិកជាតិសម្រាប់ ប្រាំមួយខែដំបូងនៃ ឆ្នាំ២០១៥។ ដោយសារពុំមានការផ្តល់ថវិកាពេញលេញសម្រាប់ភាគីជាតិ បុគ្គលិកជាតិមិនបានទទួលប្រាក់ខែសម្រាប់ខែសីហា និងខែកញ្ញា ទោះបីមានការរំពឹងថា ថវិកានេះនឹងបានទទួលនាពេលខ្លីខាងមុខក៏ដោយ។ ទោះជាយ៉ាងណា ជាថ្មីម្តងទៀត ស្ថានភាពបច្ចុប្បន្ននេះបានប៉ះពាល់ដល់ទឹកចិត្តរបស់បុគ្គលិក ហើយប្រសិនបើមិនបានដោះស្រាយឲ្យទាន់ពេលវេលាទេ វាអាចនឹងបណ្តាលឲ្យមានការអាក់ខានដល់សកម្មភាពរបស់អង្គជំនុំជម្រះ។

១២ ការប៉ាន់ស្មានលើតារាងកំណត់ពេលវេលាខាងក្រោម ត្រូវបានធ្វើឡើងដោយផ្អែកមូលដ្ឋានថា អង្គជំនុំជម្រះនិងការិយាល័យទាំងអស់មានបុគ្គលិកគ្រប់គ្រាន់ និងថាកិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការ

---

[8] សេចក្តីសម្រេចរបស់មហាសន្និបាតលេខ 68/247B។

នឹងមិនត្រូវរំខានបន្ថែមទៀតដោយសារតែអសន្តិសុខផ្នែកហិរញ្ញវត្ថុ។ ប្រសិនបើអសន្តិសុខផ្នែកហិរញ្ញវត្ថុលេចឡើង យើងអាចចាំបាច់ត្រូវកែសម្រួលតារាងពេលវេលាឡើងវិញ។

១៣ ការប៉ាន់ស្មាននានាលើគម្រោងបញ្ចប់ផែនការជំនុំជម្រះក្តីក្នុងសំណុំរឿង០០២/០២ បណ្តឹងសាទុក្ខលើសំណុំរឿង០០២/០១ និង ការបញ្ចប់កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ និង ០០៤ សន្មត់ថាសកម្មភាពទាំងអស់ កំពុងត្រូវបានធ្វើឡើងដំណាលៗគ្នា។ ក្រុមមេធាវីការពារក្តី នួន ជា និង ខៀវ សំផន ក៏ដូចជា សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី នឹងចូលពាក់ព័ន្ធទាំងបណ្តឹងសាទុក្ខសំណុំរឿង០០២/០១ និង ការជំនុំជម្រះក្តីសំណុំរឿង០០២/០២ នៅពេលទន្ទឹមគ្នា។ សហព្រះរាជអាជ្ញានឹងចូលរួមក្នុងពេលជាមួយគ្នានៅក្នុងរឿងក្តីទាំងពីរនេះ ក្នុងចំណោមរឿងក្តីទាំងអស់ ព្រមទាំងការស៊ើបអង្កេត និង ការរៀបចំសារណាបញ្ចប់ការពិភាក្សាដេញដោលក្នុងសំណុំរឿង ០០៣ និង ០០៤។ ការិយាល័យសហព្រះរាជអាជ្ញាបានស្នើសុំធនធានបន្ថែមនៅក្នុងខ្ទង់ថវិកាឆ្នាំ២០១៥ ដែលមាន ការកែប្រែ ដើម្បីធានាឲ្យប្រាកដថា ការិយាល័យសហព្រះរាជអាជ្ញាមានស្ថិរភាពក្នុងការ បំពេញភារកិច្ចរបស់ខ្លួននៅក្នុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២/០១ សំណុំរឿង០០២/០២ សំណុំរឿង០០៣ និង សំណុំរឿង០០៤។

១៤ នៅខែមករា ឆ្នាំ២០១៥ កិច្ចប្រជុំពេញអង្គនៃ អ.វ.ត.ក បានអនុម័តវិសោធនកម្មទៅលើវិធាន ផ្ទៃក្នុងដែលអនុញ្ញាតឲ្យមានការកាត់បន្ថយទៅលើវិសាលភាពកិច្ចស៊ើបសួរល្គឹកណាវិសាលភាពស៊ើបអង្កេតដែលបានកាត់បន្ថយជាតំណាងឲ្យបទចោទ និង ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនសង្ស័យតាមការចោទប្រកាន់។ ស្រដៀងគ្នានេះដែរ អង្គជំនុំជម្រះសាលាដំបូងអាចកាត់បន្ថយវិសាលភាពនៃការជំនុំជម្រះក្តីដោយមិនរួមបញ្ចូលអង្គហេតុជាក់លាក់មួយចំនួនដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ វិសោធនកម្មទាំងនេះ ប្រសិនបើ អនុវត្តបាន គឺអាចពន្លឿនការបញ្ចប់កិច្ចនីតិវិធីស៊ើបសួរ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបន្តវាយតម្លៃទៅលើថាតើវិធានថ្មីទាំងនេះអាចយកមកអនុវត្តដើម្បីពង្រួញវិសាលភាពនៃកិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ និង ០០៤ ដែរឬយ៉ាងណា។

១៥ ក្នុងគោលបំណងបង្កើនសមត្ថភាពស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ក្រសួងយុត្តិធម៌ បានផ្តល់នីតិសម្បទាដល់មន្ត្រីច្បាប់អន្តរជាតិចំនួនប្រាំបួននាក់ ដើម្បីចុះធ្វើកំណត់ហេតុស្តាប់ចម្លើយហើយកិច្ចការនេះជាធម្មតាគឺត្រូវបំពេញដោយអ្នកស៊ើបអង្កេតប៉ុណ្ណោះ។ ការបង្កើន

សមត្ថភាពក្នុងការចុះធ្វើកំណត់ហេតុស្តាប់ចម្លើយនេះ នឹងជំរុញឲ្យដំណាក់កាលស៊ើបសួរ បានលឿន។ ជាងនេះទៀតសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចាប់អនុវត្តគំនិតផ្តួចផ្តើមនានា ដើម្បីបង្កើនធនធានមនុស្ស របស់ខ្លួនជាមួយនឹងបុគ្គលិកជំនាញក្រោមកម្មវិធីដែលមិនត្រូវសងវិញ និងកម្មសិក្សាការីបន្ថែមទៀត ដើម្បីបង្កើនផលិតផលនៃកិច្ចស៊ើបសួរ។ សមត្ថភាពបំពេញកិច្ចស៊ើបសួរត្រូវបានបង្កើនថែមទៀត នៅពេលដែលអ្នកស៊ើបអង្កេតអន្តរជាតិថ្មីបីរូបបានចូលបម្រើការងារនៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេតក្នុងត្រីមាសទី១ ឆ្នាំ២០១៥។ អ្នកស៊ើបអង្កេតអន្តរជាតិថ្មីបីរូបបំពេញកិច្ចការនេះក្នុងរយៈពេលបណ្តោះអាសន្នតែប៉ុណ្ណោះ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបន្តទាក់ទងរដ្ឋជាសមាជិក និង អង្គការវិជ្ជាជីវៈនានាក្នុងគោលបំណងជ្រើសរើសអ្នកស៊ើបអង្កេតបន្ថែមមកបំពេញការងារជាបុគ្គលិកមិនយកប្រាក់កម្រៃ។

១៦ ក្នុងអំឡុងត្រីមាសទី ៣ ក្នុងឆ្នាំ២០១៥ ការិយាល័យរដ្ឋបាលបានជ្រើសរើសបុគ្គលិកផ្នែកបកប្រែភាសាក្រៅម៉ោងមួយចំនួន ដើម្បីជួយការងារការិយាល័យ និងអង្គជំនុំជម្រះ ដើម្បីធានាឲ្យមានសេវាបកប្រែភាសាបានទាន់ពេលវេលា។

## III. ផែនការបញ្ចប់ការស៊ើបអង្កេត

១៧ តារាងកំណត់ពេលវេលានៃការបញ្ចប់ការស៊ើបអង្កេត ត្រូវបានកំណត់ដោយកត្តានានាដូចជា៖ ប្រភេទនិងភាពស្មុគស្មាញនៃរឿងក្តី ចំនួនសាក្សីដែលត្រូវស្តាប់សក្ខីកម្ម ចំនួនបេសកកម្មចុះដល់ទីកន្លែងដែលតម្រូវឲ្យមានបុគ្គលិកមានគុណវុឌ្ឍិ និងសមត្ថភាពក្នុងការរក្សាទុកបុគ្គលិកដែលមានបទពិសោធន៍ការបង្អាក់ជាក់ស្តែងនិងធនធានសម្ភារៈក្នុងការបំពេញកិច្ចស៊ើបសួរ ចំនួនញត្តិដែលដាក់ដោយភាគីនានា ថិរវេលាដែលតម្រូវដោយអង្គបុរេជំនុំជម្រះដើម្បីចេញសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បន្ធំរបស់ភាគីនានា និងការពិចារណាពាក់ព័ន្ធនានា។ ដោយមានកត្តាប្រែប្រួលទាំងនេះ ការស្មានទុកជាមុននូវតារាងកំណត់ពេលវេលាអនុវត្តគ្រោងការ អាចផ្អែកលើបទពិសោធន៍កន្លងទៅទាំងនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ និងក្នុងស្ថាប័នតុលាការប្រហាក់ប្រហែលគ្នានេះ។

១៨ វិធានផ្ទៃក្នុងដាក់បញ្ញត្តិអំពីដំណាក់កាលនីតិវិធីផ្សេងៗ ដែលសហចៅក្រមស៊ើបអង្កេតត្រូវអនុវត្តតាមដើម្បីបំពេញឲ្យបានពេញលេញនូវដំណើរការស៊ើបអង្កេត។ សហចៅក្រមស៊ើបអង្កេតត្រូវស៊ើបអង្កេត

អង្គហេតុនានាដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ដែលដាក់ដោយសហព្រះរាជអាជ្ញា។ នៅពេលបំពេញកិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេតអាចនឹងបំពេញកិច្ចស៊ើបសួរ ដែលនាំឲ្យបញ្ជាក់នូវការពិត។ នៅគ្រប់ករណីទាំងអស់ ពួកគេត្រូវបំពេញកិច្ចស៊ើបសួរដោយអនាគតិ។ ភាគីនានាអាចស្នើសុំសហចៅក្រមស៊ើបអង្កេតបំពេញកិច្ចស៊ើបសួរជាក់លាក់មួយចំនួន។ ការបដិសេធមិនពិចារណាលើសំណើសុំ អាចនឹងត្រូវបានប្ដឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ។ បុគ្គលទាំងឡាយដែលត្រូវបានចោទប្រកាន់ ក្នុងនាមជាភាគីនៅក្នុងកិច្ចដំណើរការនីតិវិធី គឺបច្ចុប្បន្ននេះមានសិទ្ធិចូលពិនិត្យមើលសំណុំរឿងតាមរយៈមេធាវីរបស់ពួកគេ។ ប្រការនេះនឹងអនុញ្ញាតឲ្យពួកគេចូលរួមនៅក្នុងកិច្ចស៊ើបសួរតាមរយៈការធ្វើសំណើសុំបំពេញកិច្ចស៊ើបសួរ ក៏ដូចជាតវ៉ានឹងដីកា និងសេចក្ដីសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេត។ ក្រុមមេធាវីការពារក្ដីនៃជនត្រូវចោទទាំងបីនាក់ នឹងត្រូវផ្ដល់នូវពេលវេលាសមរម្យនៅក្នុងកំឡុងត្រីមាសទី១ ឆ្នាំ២០១៥ ក្នុងការពិនិត្យសំណុំរឿង ដែលស្របទៅនឹងតម្រូវការនៃដំណើរការត្រឹមត្រូវ និងស្នើសុំបំពេញកិច្ចស៊ើបសួរ។

១៩ នៅពេលសហចៅក្រមស៊ើបអង្កេតពិចារណាឃើញថា ការស៊ើបអង្កេតត្រូវបានបញ្ចប់ សហចៅក្រមស៊ើបអង្កេតត្រូវជូនដំណឹងដល់ភាគីទាំងអស់។ ភាគីមានរយៈពេល១៥ថ្ងៃដើម្បីស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរបន្ថែម លើកលែងតែភាគីបោះបង់រយៈពេលនោះចោល។ ប្រសិនបើសហចៅក្រមស៊ើបអង្កេត សម្រេចបដិសេធចោលសំណើបែបនេះ សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាសម្រេចមួយដែលមានសំអាងហេតុ។ នៅក្នុងរយៈពេល៣០ថ្ងៃបន្ទាប់ពីការជូនដំណឹងអំពីដីកាសម្រេចនេះ ភាគីទាំងអស់អាចដាក់បណ្ដឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ។ នៅពេលដែលរយៈពេលនេះបានផុតកំណត់ ត្រូវបានបោះបង់ចោល ឬបណ្ដឹងឧទ្ធរណ៍ដែលបានលើកឡើងខាងលើត្រូវបានជំនុំជម្រះ សហចៅក្រមស៊ើបអង្កេតត្រូវបញ្ជូនសំណុំរឿងភ្លាមៗទៅឲ្យសហព្រះរាជអាជ្ញា ដើម្បីចេញដីកាសន្និដ្ឋានស្ថាពរ។ សហព្រះរាជអាជ្ញាត្រូវចេញដីកាសន្និដ្ឋានស្ថាពរជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ និងបង្វិលសំណុំរឿងឲ្យសហចៅក្រមស៊ើបអង្កេត នៅក្នុងរយៈពេល៤៥ថ្ងៃ ប្រសិនបើជនត្រូវចោទត្រូវបានឃុំខ្លួន និងរយៈពេល៣ខែនៅក្នុងរឿងក្ដីផ្សេងទៀត។ លើកលែងតែក្រោយពេលដំណាក់កាលដែលលើកឡើងខាងលើនេះត្រូវបានបញ្ចប់ សហចៅក្រមស៊ើបអង្កេតនឹងចេញដីកាដំណោះស្រាយថាតើត្រូវចោទប្រកាន់ជនត្រូវចោទ ដែលត្រូវបញ្ជូនរូបគាត់ទៅជំនុំជម្រះ ឬត្រូវទម្លាក់ចោលការចោទ

ប្រកាន់។ សហព្រះរាជអាជ្ញាអាចនឹងដាក់បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយទៅអង្គបុរេជំនុំជម្រះ ចំណែកឯដើមបណ្ដឹងរដ្ឋប្បវេណីអាចដាក់បណ្ដឹងឧទ្ធរណ៍ តែក្នុងករណីដីកាដំណោះស្រាយបដិសេធចោលការចោទប្រកាន់ និងក្នុងករណីដែលសហព្រះរាជអាជ្ញាបានប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធចោលការចោទប្រកាន់នេះ។ បន្ថែមពីលើនេះ អង្គបុរេជំនុំជម្រះបានផ្ដល់នូវសិទ្ធិឲ្យជនត្រូវចោទជំទាស់នឹងធាតុផ្សំយុត្តាធិការនៅក្នុងដីកាដំណោះស្រាយតាមរយៈបណ្ដឹងឧទ្ធរណ៍។ បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ត្រូវតែដាក់នៅក្នុងរយៈពេល៣០ថ្ងៃ បន្ទាប់ពីការជូនដំណឹងអំពីដីកាសម្រេចនេះ។ អង្គបុរេជំនុំជម្រះអាចនឹងកែប្រែ ឬតម្កល់ដីកាដំណោះស្រាយនេះ។

២០ កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ និង ០០៤ បានចាប់ផ្ដើមដំណើរការក្រោយពីការបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញាអន្តរជាតិនៅខែកញ្ញាឆ្នាំ២០០៩។ ដោយអនុលោមតាមវិធានផ្ទៃក្នុងនៃ អ.វ.ត.ក សហចៅក្រមស៊ើបអង្កេតបានធ្វើកំណត់ហេតុនៃការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេតជាតិ និងសហចៅក្រមស៊ើបអង្កេតអន្តរជាតិពាក់ព័ន្ធនឹងកិច្ចស៊ើបសួរក្នុងសំណុំរឿងទាំងនេះ។ ហេតុដូចនេះ សហចៅក្រមស៊ើបអង្កេតទាំងពីររូបកំពុងតែជ្រើសរើសវិធីសាស្ត្ររៀងៗខ្លួននៅក្នុងសំណុំរឿងទាំងនេះ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិកំពុងតែស៊ើបអង្កេតយ៉ាងសកម្មលើការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នៅមូលដ្ឋានបទល្មើសចំនួនជាង១០ផ្សេងៗពីគ្នាក្នុងសំណុំរឿង០០៣ និងមូលដ្ឋានបទល្មើសចំនួន៥៥ក្នុងសំណុំរឿង ០០៤។

២១ ដោយសារតែភាពខុសគ្នានៃស្ថានភាពស៊ើបអង្កេតលើជនជាប់ចោទបីរូបក្នុងសំណុំរឿង ០០៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបន្តពិចារណាទៅលើជម្រើសចំនួនពីរ ក) សំណុំរឿង ០០៤ អាចត្រូវបានបំបែក ក្នុងនោះ សេចក្ដីជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរចំនួនពីរអាចនឹងចេញនៅត្រឹមត្រីមាសទី ៤ ក្នុងឆ្នាំ ២០១៥ ហើយសេចក្ដីជូនដំណឹងទី ៣ អាចនឹងចេញនៅត្រឹមត្រីមាសទី ១ ក្នុងឆ្នាំ ២០១៦ ខ) ឬ សំណុំរឿង ០០៤ អាចទុកនៅដដែល ហើយក្នុងករណីនេះ ការស៊ើបអង្កេតនេះអាចបញ្ចប់នៅត្រឹមត្រីមាសទី ១ ក្នុងឆ្នាំ ២០១៦។ ប្រសិនបើសំណុំរឿង ០០៤ ត្រូវបានបំបែក យើងប៉ាន់ស្មានថាដីកាដំណោះស្រាយអាចនឹងត្រូវចេញនៅត្រឹមត្រីមាសទី ១ ត្រីមាសទី ៣ និងត្រីមាសទី ៤ ក្នុងឆ្នាំ ២០១៦។ ប្រសិនបើសំណុំរឿង ០០៤ មិនត្រូវបានបំបែក យើងប៉ាន់ស្មានថា សេចក្ដីសម្រេចក្នុងទម្រង់

ជាដីកាដំណោះស្រាយទៅលើចំណុចថាតើត្រូវចោទប្រកាន់បញ្ជូនជនជាប់ចោទទៅជំនុំជម្រះ ឬក៏អត់នោះ អាចនឹងចេញនៅត្រឹមត្រីមាសទី ៤ ក្នុងឆ្នាំ ២០១៦។

២២ ដូចបានកត់សម្គាល់ខាងលើ សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលទើបនឹងតែងតាំងថ្មីៗកំពុងពិនិត្យមើលឡើងវិញទៅលើទំហំការងារដែលនៅសេសសល់ និងការព្យាករណ៍ពេលវេលានៅក្នុងសំណុំរឿង ០០៣ និងសំណុំរឿង ០០៤។ ការងារពិនិត្យមើលឡើងវិញនេះនឹងបន្តធ្វើរហូតដល់ចុងត្រីមាសក្នុងឆ្នាំ ២០១៥ ហើយការកែប្រែជាបន្តលើការព្យាករណ៍ពេលវេលាទាំងនេះ នឹងត្រូវដាក់បញ្ចូលទៅក្នុងផែនការបញ្ចប់ អ.វ.ត.ក លើកក្រោយទៀត។

២៣ អាស្រ័យលើការកែប្រែទៅតាមការពិនិត្យមើលឡើងវិញដែលកំពុងបន្តធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ការព្យាករណ៍ដ៏សុក្រឹតដែលអាចផ្តល់ជូនបាននៅពេលនេះគឺ៖

(i) កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ នឹងត្រូវបញ្ចប់ ត្រឹម ត្រីមាសទី៤ ឆ្នាំ ២០១៥

(ii) កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៤ នឹងត្រូវបញ្ចប់នៅត្រីមាសទី៤ ឆ្នាំ២០១៥ និង/ឬត្រីមាសទី១ ឆ្នាំ២០១៦ អាស្រ័យ លើថាតើសំណុំរឿងនេះនឹងត្រូវបំបែក ឬអត់

(iii) ដីកាដំណោះស្រាយក្នុងសំណុំរឿង០០៣ នឹងត្រូវចេញនៅត្រីមាសទី៣ ឆ្នាំ ២០១៦

(iv) ដីកាដំណោះស្រាយ(មួយឬច្រើន)ក្នុងសំណុំរឿង០០៤ នឹងត្រូវចេញនៅត្រីមាសទី១ ត្រីមាសទី៣ ឬត្រីមាសទី៤ ឆ្នាំ២០១៦ អាស្រ័យលើថាតើសំណុំរឿងនេះនឹងត្រូវបំបែកឬអត់ និង

(v) រាល់បណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយនឹងត្រូវសម្រេចសេចក្តីដោយអង្គបុរេជំនុំជម្រះនៅត្រីមាសទី១ ឆ្នាំ២០១៧ សម្រាប់សំណុំរឿង០០៣ និងត្រីមាសទី២ ឆ្នាំ២០១៧ សម្រាប់សំណុំរឿង០០៤។

២៤ ការប៉ាន់ប្រមាណពេលវេលាទាំងនេះនៅតែអាស្រ័យទៅលើកត្តាជាច្រើនដូចដែលបានកំណត់កាលពីមុន ដូចជា៖ ពុំមានការចាកចេញ របស់បុគ្គលិកសំខាន់ៗ ការជ្រើសរើសបុគ្គលិកថ្មីទៅតាមតំណែងដែលនៅទំនេរ ការបកប្រែឯកសារ ទាន់ពេលវេលា សមត្ថភាពបកប្រែផ្ទាល់មាត់និងការធ្វើប្រតិចារឹក

គ្រប់គ្រាន់សម្រាប់បេសកកម្មនៅ នៅតាមមូលដ្ឋាន និង ការសម្ភាសន៍សាក្សី ដំណោះស្រាយទាន់ពេលវេលាទៅលើបណ្ដឹងឧទ្ធរណ៍នៅ អង្គបុរេជំនុំជម្រះ និង ការគាំទ្រពេញលេញពីសំណាក់នគរបាលយុត្តិធម៌ក្នុងការប្រគល់ដីកា និង ការអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួនទាំងឡាយ។

## IV. ផែនការបញ្ចប់សវនាការ

២៥ តារាងពេលវេលានៃការបញ្ចប់សវនាការត្រូវកំណត់ដោយកត្តានានាដូចជា៖ លក្ខណៈ និងភាពស្មុគស្មាញនៃសំណុំរឿង បញ្ហាសុខភាពរបស់ជនជាប់ចោទដែលមានវ័យចាស់ជរា ចំនួនសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលត្រូវកោះហៅ និងរយៈពេលនៃការធ្វើសក្ខីកម្មរបស់សាក្សីទាំងនោះ ការបង្អាក់ជាក់ស្ដែងនានាក្នុងការបំពេញកិច្ចដំណើរការនីតិវិធី ចំនួនញត្តិដាក់ដោយភាគី និងការពិនិត្យពិច័យផ្នែករដ្ឋបាលផ្សេងៗទៀត ក្នុងនោះរួមមានការបកប្រែផ្ទាល់មាត់បានត្រឹមត្រូវ និង ការបកប្រែឯកសារទាន់ពេលវេលា។ ដោយមានកត្តាប្រែប្រួលទាំងនេះ ការស្មានទុកជាមុននូវតារាងកំណត់ពេលវេលាអនុវត្តគ្រោងការ គឺផ្អែកលើបទពិសោធន៍កន្លងទៅ ទាំងនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ និងស្ថាប័នតុលាការប្រហាក់ប្រហែលគ្នានេះ។

២៦ ការប្រជុំរៀបចំសវនាការចំនួនមួយ ឬច្រើន តែងតែបានរៀបចំឡើងមុនពេលការចាប់ផ្ដើមសវនាការជាក់ស្ដែង។ សវនាការចាប់ផ្ដើមដោយសវនាការបឋម។ នៅក្នុងសវនាការបឋមនេះ អង្គជំនុំជម្រះសាលាដំបូង ពិចារណាទៅលើបញ្ជីសាក្សីសក្ខីទុពល និងអ្នកជំនាញ ដែលដាក់ជូនដោយភាគី ព្រមទាំងអញ្ញត្រកម្ម លើកឡើងដោយភាគី ហើយភាគីដើមបណ្ដឹងរដ្ឋប្បវេណីអាចផ្ដួចផ្ដើមនូវចំណុចជាក់លាក់អំពីសំណងដែលខ្លួនស្នើសុំ។ សវនាការលើអង្គសេចក្ដីចាប់ផ្ដើមដោយមានការធ្វើសេចក្ដីសន្និដ្ឋានដោយសង្ខេបពីសំណាក់សហព្រះរាជអាជ្ញា ហើយជនជាប់ចោទអាចធ្វើការឆ្លើយតបដោយសង្ខេបបាន មុនពេលអង្គជំនុំជម្រះសាលាដំបូង ចាប់ផ្ដើមតាំងសំណួរដល់ជនជាប់ចោទ ភាគីដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សី និងស្ដាប់នូវការបង្ហាញភស្តុតាង។ សហព្រះរាជអាជ្ញាមានបន្ទុកបញ្ជាក់អំពីពិរុទ្ធភាពរបស់ជនជាប់ចោទ។ ដើម្បីផ្ដន្ទាទោសជនជាប់ចោទអង្គជំនុំជម្រះសាលាដំបូងត្រូវមានជំនឿ ដោយគ្មានវិមតិសង្ស័យអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ។ ក្រោយពេលពិនិត្យភស្តុតាងទាំងអស់រួចហើយ អង្គជំនុំជម្រះស្ដាប់ការបិទកិច្ចពិភាក្សាដេញដោលពីសំណាក់ភាគី មុនពេលពិភាក្សាគ្នាជាសម្ងាត់ដើម្បីសម្រេចសេចក្ដី។ ប្រសិនបើជនជាប់ចោទត្រូវផ្ដន្ទាទោស អង្គជំនុំជម្រះសម្រេចទៅលើ

ទោសសមស្របដែលបានកំណត់នៅក្នុងសាលក្រមរបស់ខ្លួន។ ដោយឈរលើមូលដ្ឋាននៃជំហាននីតិវិធីទាំងនេះទើបយើងកំណត់បាននូវគ្រោងការសំខាន់ៗផ្សេងៗគ្នាសម្រាប់សវនាការនីមួយៗបាន។

## ក. <u>សំណុំរឿង០០២/០២</u>

២៧ នៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានចេញនូវសេចក្តីសម្រេចបំបែកសំណុំរឿងថ្មីមួយទៀត ដោយកំណត់វិសាលភាពក្នុងសំណុំរឿង០០២/០២ ដែលជាការជំនុំជម្រះក្តីវគ្គទីពីរប្រឆាំងនឹងខៀវ សំផន និង នួន ជា។ អង្គជំនុំជម្រះសាលាដំបូង សម្រេចថា ទីតាំងបទល្មើស ដែលបានចោទប្រកាន់ និងការចោទប្រកាន់តាមអង្គហេតុបង្កើតបានជា មូលដ្ឋាននៃសំណុំរឿង០០២/០២៖ អំពើប្រល័យពូជសាសន៍លើជនជាតិចាម និងជនជាតិវៀតណាម (មិនរាប់បញ្ចូលឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយកងទ័ពបដិវត្តកម្ពុជា នៅលើទឹកដីវៀតណាម) ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងរំលោភ (ទូទាំងប្រទេស) ការបោសសម្អាតផ្ទៃក្នុង មន្ទីរសន្តិសុខ ស២១ មន្ទីរសន្តិសុខ ក្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង និងមន្ទីរសន្តិសុខភ្នំក្រោល ការដ្ឋានទំនប់១មករា ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង ការដ្ឋានទំនប់ត្រពាំងថ្ម សហករណ៍នៅត្រាំកក់ ការប្រព្រឹត្តិមកលើពុទ្ធសាសនិក (កម្រិតត្រឹមតែសហករណ៍ត្រាំកក់) និងការដៅលើអតីតអ្នកមុខអ្នកការរបបសាធារណរដ្ឋខ្មែរ (ការអនុវត្តកម្រិតត្រឹមតែសហករណ៍ត្រាំកក់ ការដ្ឋានទំនប់១មករា មន្ទីសន្តិសុខ ស២១ និងមន្ទីរសន្តិសុខក្រាំងតាចាន់)។ នៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ អង្គជំនុំជម្រះតុលាការកំពូលតម្កល់សេចក្តីសម្រេចបំបែកសំណុំរឿងថ្មីនេះ។

២៨ អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការបឋមបន្ថែមទៀតក្នុងសំណុំរឿង ០០២/០២ នៅថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៤។ នៅក្នុងសវនាការនោះ អង្គជំនុំជម្រះសាលាដំបូង ស្តាប់សារណារបស់ភាគីទៅលើលំដាប់លំដោយនៃនីតិវិធីជំនុំជម្រះបន្ថែមទៅលើសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់ខ្លួនលើវិសាលភាពនៃសំណុំរឿង០០២/០២ ហើយនិងសំណើរបស់ភាគីទាក់ទងនឹងសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលត្រូវស្តាប់សក្ខីកម្ម។ អង្គជំនុំជម្រះក៏បានផ្តល់ឱកាសដល់ដើមបណ្តឹងរដ្ឋប្បវេណីបង្ហាញនូវបញ្ហាកាន់តែជាក់លាក់ថែមទៀតទៅលើសំណងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី។

២៩ នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សេចក្តីសន្និដ្ឋានចោទប្រកាន់របស់សហព្រះរាជអាជ្ញាជាតិនិងអន្តរជាតិ។ បន្ទាប់មក ខៀវ សំផន និង នួន ជា បានបង្ហាញភាពមិនពេញចិត្តចង់ចូលរួមក្នុង កិច្ចនីតិវិធី ក្នុងសំណុំរឿង០០២/០២ លុះត្រាតែមានដំណោះស្រាយទៅលើបញ្ហាជាក់លាក់នានា ហើយ បានបង្គាប់ឱ្យមេធាវីការពារក្តីរបស់ខ្លួនអនុវត្តទៅតាមការណែនាំរបស់ខ្លួន។ នួន ជា បានចូលរួមសាជាថ្មីនៅក្នុងសំណុំរឿង០០២/០២ នៅថ្ងៃទី១៧ ខែវិច្ឆិកា ចំណែកឯមេធាវីការពារក្តី ខៀវ សំផន បន្តពហិការមិនចូលរួមក្នុងកិច្ចដំណើរការនីតិវិធី ដោយបង្ខំឱ្យអង្គជំនុំជម្រះសាលាដំបូងផ្អាកកិច្ចនីតិវិធីសវនាការលើភស្តុតាង រហូតដល់ ខែមករា ឆ្នាំ២០១៥។

៣០ កិច្ចដំណើរការនីតិវិធីលើភស្តុតាងបានចាប់ផ្តើមនៅថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥ ដោយអង្គជំនុំជម្រះត្រូវធ្វើសវនាការចំនួនបីថ្ងៃក្នុងមួយសប្តាហ៍។លទ្ធផលនៃការវាយតម្លៃផ្នែកវេជ្ជសាស្ត្ររបស់ជនជាប់ចោទនៅខែមករា ឆ្នាំ២០១៥បង្ហាញថា ការកំណត់៤ថ្ងៃក្នុង១សប្តាហ៍ជាការសមស្រប ដោយសវនាការពេលព្រឹកធ្វើឱ្យបានខ្លីបន្តិច។ ដូច្នេះអង្គជំនុំជម្រះបានត្រឡប់ទៅអនុវត្តតាមពេលកំណត់៤ថ្ងៃក្នុង១សប្តាហ៍វិញ នៅខែកុម្ភៈ ឆ្នាំ២០១៥ ដែលជាការពន្លឿនដល់ការជំនុំជម្រះក្តី។ គិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៥ អង្គជំនុំជម្រះបានស្តាប់ សក្ខីកម្មសាក្សីសរុបចំនួន៤៦ ដើមបណ្តឹងរដ្ឋប្បវេណីសរុបចំនួន៣១ និង អ្នកជំនាញចំនួន១នាក់ នៅលើប្រធានបទសហករណ៍ត្រាំកក់ ការដ្ឋានទំនប់១មករា ការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង ការដ្ឋានទំនប់ត្រពាំងថ្ម និងការប្រព្រឹត្តិលើជនជាតិចាម។ អង្គជំនុំជម្រះក៏បានជម្រាបដល់ភាគីអំពីបញ្ជីឈ្មោះសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីបណ្តោះអាសន្នចំនួន១១នាក់ ដែលនឹងត្រូវផ្តល់សក្ខីកម្មអំពីការប្រព្រឹត្តិលើជនជាតិវៀតណាម។

៣១ ចំនួនថ្ងៃសម្រាប់បើកនិងបញ្ចប់សវនាការពេញលេញ គឺអាចស្មានទុកបានក្នុងសំណុំរឿង ០០២/០២ តែនៅពេល ចំនួនទូទៅនៃសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលត្រូវកោះហៅ មានការកំណត់ច្បាស់លាស់ហើយដោយអង្គជំនុំជម្រះសាលាដំបូង។ សក្ខីកម្មសរុបចំនួន ២៦៥ ត្រូវបានស្នើឡើងដំបូងដោយភាគី។ សក្ខីកម្មសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីថ្មីបន្ថែមចំនួន ៤០ នាក់ទៀត ត្រូវបានស្នើឡើងចាប់តាំងពីការចាប់ផ្តើមការជំនុំជម្រះមកម្ល៉េះ។ ការស្មានទុកពេលទាក់ទិននឹងសំណុំរឿង០០២/០២ គឺផ្អែកទៅលើការសន្មតថា សវនាការទីពីរនឹងមានលក្ខណៈស្មុគស្មាញ និងត្រូវការពេលវេលាដូចគ្នានឹងសវនាការ០០២/០១ ដែរ ប៉ុន្តែអាចខុសប្លែកពីគ្នាច្រើន នៅពេលដែលកត្តានេះត្រូវ

01739859

បានកំណត់ពេញលេញ។ ចាប់តាំងពីការបើកសវនាការលើភស្តុតាងជាថ្មី នៅខែមករា ពុំមានសញ្ញាណបញ្ជាក់អំពីការធ្វើពហិការសាជាថ្មីឡើយ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី វាអាចជាការចាំបាច់សម្រាប់អង្គជំនុំជម្រះកែតម្រូវទៅលើការគ្រោងទុក សកម្មភាពសំខាន់ៗដើម្បីផ្ទុះ គ្នាជាមួយនឹងការបាត់បង់រយៈពេល៣ខែទៅលើការពហិការកន្លងទៅ។

៣២ ចំពោះកត្តានានាដែលអាចទាក់ទិននឹងរយៈពេលនៃជំនុំជម្រះដែលស្មានទុក ដែលអាចនឹងកើតឡើងនៅថ្ងៃអនាគត ការប្រែប្រួលស្ថានភាពសុខភាពរបស់ជនជាប់ចោទ ដែលធ្វើឲ្យមានតម្រូវកា កាត់បន្ថយចំនួនថ្ងៃសវនាការក្នុងមួយសប្តាហ៍ និង/ឬរយៈពេលនៃថ្ងៃមានសវនាការ នឹងមានផលប៉ះពាល់ដោយផ្ទាល់។ នីតិវិធីបណ្តឹងសាទុក្ខ ប្រឆាំងសាលក្រមសំណុំរឿង០០២/០១ ដូចជាសវនាការឬសារណាបន្ថែមជាដើម ក៏អាចប៉ះពាល់ថែមទៀតទៅលើវត្តមានរបស់ភាគីក្នុងការចូលរួមសវនាការលើអង្គសេចក្តីក្នុងសំណុំរឿង០០២/០២ ដែលកំណត់កាលបរិច្ឆេទដូចគ្នាសំណុំរឿង០០២/០១ក៏អាចមានផលប៉ះពាល់ដល់ភាពទំនេររបស់ភាគី ក្នុងការចូលរួមសវនាការលើអង្គសេចក្តីក្នុងសំណុំរឿង០០២/០២ផងដែរ។ ការកែតម្រូវបែបនេះក៏អាចត្រូវការពិចារណាទៅលើបញ្ហានានាដែលទាក់ទិននឹងការដាក់បង្ហាញឯកសារពីសំណុំរឿង០០៣និង០០៤ដែលកំពុងតែដំណើរការផងដែរ។ ក្នុងត្រីមាស មុនការដាក់បង្ហាញចម្លើយសាក្សីពាក់ព័ន្ធរាប់រយពីការស៊ើបអង្កេតសំណុំរឿង០០៣ និង ០០៤ ដល់ភាគីក្នុងសំណុំរឿង០០២ មកដល់ពេលនេះបានតម្រូវឲ្យអង្គជំនុំជម្រះផ្អាកសវនាការមួយចំនួន។ ការដាក់បង្ហាញឯកសារនេះនាំឲ្យមានសំណើពីភាគីសុំស្តាប់សក្ខីកម្មសាក្សីថែមទៀត។ ការដាក់បង្ហាញចម្លើយសាក្សីបន្ថែមនឹងកើតមានឡើង ហើយបើផ្អែកលើទំហំវានឹងតម្រូវឲ្យមានការលើកពេលបន្ថែមទៀត។ អង្គជំនុំជម្រះសាលាដំបូងបានសំដែងការព្រួយបារម្ភបន្ថែមទៀតដល់ ការិយាល័យរដ្ឋបាល ពាក់ព័ន្ធនឹងការបកប្រែផ្ទាល់មាត់ និង ការបកប្រែឯកសារ ព្រមទាំងសក្តានុពលនៃការពន្យារពេល ដែលអាចស្តែងចេញប្រសិនបើការព្រួយបារម្ភទាំងនេះមិនត្រូវបានដោះស្រាយ។ ការិយាល័យរដ្ឋបាលបានចាត់វិធានការដោះស្រាយបញ្ហានេះ និងកំពុងបន្តពិនិត្យមើលបញ្ហានេះរហូតមក។

៣៣ ដោយសារនៅសល់ការជំនុំជម្រះក្តីមួយផ្នែកធំ ហើយការដាក់បង្ហាញបញ្ហានេះកំពុងបន្តធ្វើឡើង ដូច្នេះអង្គជំនុំជម្រះមិនអាចកំណត់បានរយៈពេលដែលចាំបាច់ត្រូវពន្លាតចំពោះកិច្ចដំណើរការនីតិវិធីក្រោយពី

01739860

មានពហិការកន្លងទៅ ការដាក់បង្ហាញឯកសារ និងបញ្ហាផ្សេងៗទៀត។ អង្គជំនុំជម្រះគួរតែអាចធ្វើដូច្នេះបាននៅចុងឆ្នាំនេះ។

## ខ. <u>បទចោទដែលនៅសេសសល់/ការចោទប្រកាន់តាមអង្គហេតុក្នុងសំណុំរឿង០០២</u>

៣៤ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន នៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ អង្គជំនុំជម្រះតុលាការកំពូលប្រកាសផ្អាកដំណើរការនីតិវិធីពាក់ព័ន្ធនឹងបទចោទដែលនៅសល់ ដែលស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង០០២/០១ និង ០០២/០២ ដោយរង់ចាំសេចក្តីសម្រេចសមស្រប របស់អង្គជំនុំជម្រះសាលាដំបូង។ អង្គជំនុំជម្រះតុលាការកំពូលលើកឡើងម្តងទៀតថាអង្គជំនុំជម្រះសាលាដំបូងមានករណីកិច្ចកាត់សេចក្តី ឬចេញសេចក្តីសម្រេចទៅលើបទចោទដែលនៅសល់ក្នុងសំណុំរឿង០០២ អនុលោមតាមក្រមខ័ណ្ឌគតិយុត្តិ និងជំរុញឲ្យអង្គជំនុំជម្រះសាលាដំបូងអនុវត្តទៅតាមករណីកិច្ចនេះ។ មកដល់ពេលនេះ អង្គជំនុំជម្រះពុំទាន់បានទទួលសំណើណាមួយទាក់ទិននឹងបញ្ហានេះទេ។ បញ្ហានេះនៅតែស្ថិតក្នុងការពិចារណាដដែល។

## គ. <u>សំណុំរឿង០០៣ និង សំណុំរឿង០០៤</u>

៣៥ លុះត្រាតែមានសេចក្តីសម្រេចថាតើ សំណុំរឿង០០៣ និង/ឬ០០៤ ត្រូវបញ្ជូនទៅជំនុំជម្រះ ទើបអាចធ្វើការស្មានទុកបានទៅលើរយៈពេលសម្រាប់បញ្ចប់ការជំនុំជម្រះក្តីទាំងនេះបាន។ ការវាយតម្លៃលើពេលវេលាដែលតម្រូវ អាចផ្អែកទៅលើចំនួនចុងចោទ ក៏ដូចជាចំនួន និងភាពស្មុគស្មាញនៃអង្គហេតុ និងអង្គច្បាប់នៃបទចោទ និងទីតាំងប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

# V. ផែនការបញ្ចប់បណ្តឹងសាទុក្ខ

៣៦ ដើម្បីធ្វើការប៉ាន់ស្មានអំពីរយៈពេលសម្រាប់ដំណើរការនីតិវិធីបណ្តឹងសាទុក្ខ ដំណាក់កាលនៃបណ្តឹងសាទុក្ខធំៗចំនួនបីត្រូវតែញែកដូចតទៅ៖ ដំណាក់កាលទីមួយ គឺត្រូវការពេលវេលាសម្រាប់ដាក់សារណារបស់ភាគីទាំងអស់។ អនុលោមតាមវិធានផ្ទៃក្នុង ភាគីត្រូវដាក់សេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខក្នុងរយៈពេល៣០ ថ្ងៃក្រោយពីការប្រកាសសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង។ ក្នុង

ករណីដែលមានបណ្ដឹងសាទុក្ខ ដោយភាគីណាមួយ ភាគីដទៃទៀតមានរយៈពេលបន្ថែម១៥ ថ្ងៃទៀត ដើម្បីដាក់សេចក្ដីសុំប្ដឹងសាទុក្ខ។ វិធានផ្ទៃក្នុងចែងថាម្ចាស់បណ្ដឹងសាទុក្ខត្រូវដាក់ជូនសារណាបណ្ដឹងសាទុក្ខក្នុងរយៈពេល ៦០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងពីការប្ដឹងសាទុក្ខ។ ភាគីនឹងមានរយៈពេល១០ថ្ងៃក្នុង ការដាក់ចម្លើយតបទៅនឹងសារណាបណ្ដឹងសាទុក្ខរបស់ភាគីដទៃទៀត។ ប៉ុន្តែកាលពីពេលកន្លងទៅ អង្គជំនុំជម្រះបានផ្ដល់ជូនរយៈពេលបន្ថែមសមរម្យសម្រាប់ដាក់ចម្លើយតប។ ក្នុងអំឡុងពេលនេះ អង្គជំនុំជម្រះតុលាការកំពូលនឹងស្រាវជ្រាវទៅលើបញ្ហាច្បាប់ និងអង្គហេតុដែលពាក់ព័ន្ធ ដើម្បីរៀបចំខ្លួនពេញលេញសម្រាប់សវនាការលើបណ្ដឹងសាទុក្ខដែលជាដំណាក់កាលទីពីរ។ ដោយត្រូវគោរពតាមលក្ខខណ្ឌមួយចំនួន ភាគីក៏មានសិទ្ធិស្នើសុំស្ដាប់ភស្តុតាងបន្ថែមនៅក្នុងបណ្ដឹងសាទុក្ខ ដែលអាចតម្រូវឱ្យអង្គជំនុំជម្រះតុលាការកំពូលរៀបចំសវនាការពិនិត្យភស្តុតាង។ បណ្ដឹងសាទុក្ខ ដែលភាគីធ្វើសារណាលើអង្គហេតុដោយផ្ទាល់មាត់នៅចំពោះមុខអង្គជំនុំជម្រះ អាចត្រូវបានបង្គាប់ឱ្យធ្វើ នៅពេលណាភាគីបានដាក់សារណាទាំងអស់របស់ខ្លួន និងពិនិត្យដោយអង្គជំនុំជម្រះតុលាការកំពូល និងនៅពេលមានការសម្រេចលើសំណើសុំភស្តុតាងបន្ថែមរួចហើយនោះ។ ដំណាក់កាលទីបី គឺការពិភាក្សាសម្រេចក្រោយពេលសវនាការនោះ និងការរៀបចំចេញសាលដីកាលើបណ្ដឹងសាទុក្ខ។

ក. <u>សំណុំរឿង០០២/០១</u>

៣៧ តាមសំណើរបស់ក្រុមមេធាវីការពារក្ដី ដោយពិចារណាទៅលើទំហំ និងភាពស្មុគស្មាញនៃរឿងក្ដី និងសាលក្រមអង្គជំនុំជម្រះតុលាការកំពូលបានពន្យារពេលកំណត់ដាក់ការជូនដំណឹងរបស់ក្រុមមេធាវីការពារក្ដីអំពីបណ្ដឹងសាទុក្ខលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង០០២/០១ ព្រមទាំងកាលកំណត់និងការកំណត់ចំនួនទំព័រសម្រាប់សារណាបណ្ដឹងសាទុក្ខ ដែលអនុញ្ញាតឱ្យដាក់ជាភាសាបារាំងឬអង់គ្លេសជាមុន និងសំណៅបកប្រែជាភាសាខ្មែរដាក់តាមក្រោយ។

៣៨ ក្រុមមេធាវី នួន ជា និង ខៀវ សំផន បានជូនដំណឹងអំពីបណ្ដឹងសាទុក្ខនៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤ និង សារណាលើបណ្ដឹងសាទុក្ខនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ដោយបាន ពង្រឹងមូលដ្ឋានបណ្ដឹងសាទុក្ខចំនួន២២៣ (មេធាវីការពារក្ដី នួន ជា) និង ១៤៨(មេធាវីការពារក្ដី ខៀវ សំផន) ដែលក្ដោបស្ទើរតែទាំងអស់ទៅ លើសំអាងហេតុនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំ រឿង

០០២/០១ ព្រមទាំង សេចក្តីសម្រេចនានារបស់អង្គជំនុំជម្រះសាលាដំបូង ដែលមិនត្រូវអនុញ្ញាតឲ្យប្តឹងសាទុក្ខភ្លាមៗ រហូតដល់ចេញសាលក្រមលើអង្គសេចក្តី។ មិនតែប៉ុណ្ណោះ នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤ សហព្រះរាជអាជ្ញាក៏ បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខដែលស្នើសុំត្រឹមតែការបំភ្លឺបញ្ជាក់ពីអង្គជំនុំជម្រះតុលាការ កំពូលទាក់ទិននឹងការអនុវត្តទម្រង់ទូលាយនៃសហឧក្រិដ្ឋកម្មរួម ដែលគេហៅថា "សហឧក្រិដ្ឋកម្មរួមទម្រង់ទី៣"។ សារណាបណ្តឹងសាទុក្ខនោះត្រូវបានដាក់ដោយសហព្រះរាជអាជ្ញា នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ០១៤។

៣៩ សំណៅបកប្រែជាភាសាខ្មែរ នៃសារណារបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីត្រូវបានបញ្ចប់នៅក្នុង ខែសីហា និងខែកក្កដា ឆ្នាំ២០១៥។ សវនាការលើអង្គសេចក្តីនៃបណ្តឹងសាទុក្ខមិនអាចកំណត់ពេលវេលាបានទេ រហូតទាល់តែសារណា និងសារណាតបមានជាភាសាខ្មែរ និងអង់គ្លេសឬបារាំង។ ហេតុដូច្នេះកត្តាមួយទៀតដែលប៉ះពាល់យ៉ាង ខ្លាំងដល់ដំណើរការនីតិវិធីបណ្តឹង សាទុក្ខបានបង្ហាញឲ្យឃើញថាវា អាស្រ័យទៅលើការបកប្រែសារណាបណ្តឹងសាទុក្ខ ជាពិសេសការបកប្រែពីភាសាអង់គ្លេសទៅភាសាខ្មែរ។

៤០ បន្ថែមលើការដាក់សារណាលើអង្គសេចក្តីនៅក្នុងបណ្តឹងសាទុក្ខ គ្រោងការទាំងនេះបានផ្អែកលើករណីដែលថា មេធាវីការពារក្តី នួន ជា បានអនុវត្តសិទ្ធិផ្នែកនីតិវិធីយ៉ាងច្រើនរបស់គាត់ ហើយបានដាក់ញត្តិចំនួន ៦ ដាច់ដោយឡែកពីគ្នាសម្រាប់ភស្តុតាងបន្ថែមលើបណ្តឹងសាទុក្ខចាប់តាំងពីការចេញសាលក្រមក្នុងសំណុំរឿង០០២/០១មកម្ល៉េះ។ ញត្តិទាំងនេះមួយភាគធំគឺជាលទ្ធផលនៃការដាក់បង្ហាញភស្តុតាងដែលកំពុងតែដំណើរការទៅក្នុងសំណុំរឿង ០០៣ និង ០០៤ ដែលញត្តិចុងក្រោយគេបង្អស់ត្រូវបានដាក់នៅថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ២០១៥ ហើយជាលទ្ធផលនៃការដាក់បង្ហាញភស្តុតាងដែលកំពុងបន្តធ្វើឡើងនៅក្នុងសំណុំរឿង ០០២/០២ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ ទំនងជាអាចនឹងមានការដាក់ញត្តិបន្ថែមសម្រាប់ភស្តុតាងបន្ថែម ដែលអាចជះឥទ្ធិពលទៅលើការកំណត់ពេលវេលាសម្រាប់បណ្តឹងសាទុក្ខលើការដាក់បង្ហាញឯកសារ។ ដោយសារមានសំណើសុំភស្តុតាងបន្ថែមនេះហើយ ទើបអង្គជំនុំជម្រះតុលាការកំពូលបានសម្រេចមួយចំនួន ក្នុងនោះរួមមានការចាប់ផ្តើមធ្វើការស៊ើបអង្កេតបន្ថែមមួយចំនួនតូច ព្រមទាំងកោះហៅសាក្សីសាក្សីបីនាក់លើបណ្តឹងសាទុក្ខ។ សវនាការ

ស្តាប់សក្ខីកម្មរបស់សាក្សីចំនួនបីនាក់នេះបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី២ ដល់ ថ្ងៃទី៦ ខែកក្កដា ឆ្នាំ ២០១៥។

៤១ ចូរកត់សម្គាល់ជាពិសេសទៅលើកាលៈទេសៈពិសេសរបស់អង្គជំនុំជម្រះតុលាការកំពូល ដែលត្រូវដោះស្រាយទៅលើសេចក្តីសម្រេចមួយចំនួន ភាគច្រើនពាក់ព័ន្ធនីតិវិធី ដែលសេចក្តីសម្រេចទាំងនោះបានធ្វើឡើងនៅក្នុងកិច្ចនីតិវិធីសវនាការ ដែលអាចប្តឹងសាទុក្ខបានតែក្រោយចេញសាលក្រមប៉ុណ្ណោះ។ ប្រការនេះមិនដូចគ្នាទៅនឹងស្ថានផាពនៅតុលាការព្រហ្មទណ្ឌអន្តរជាតិឬ សាលាក្តីមិនអចិន្ត្រៃយ៍នោះទេ ដែលនៅទីនោះ គេមានលទ្ធភាពដាក់បណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំទៅលើសេចក្តីសម្រេច ពោលគឺ នៅខណៈពេលមានសវនាការ ដើម្បីដោះស្រាយវិវាទនានាដែលកើតឡើង។ ប៉ុន្តែ អនុលោមតាមវិធាន១០៤(៤) នៃវិធានផ្ទៃក្នុង អវតក យុត្តាធិការបណ្តឹងសាទុក្ខ នៅអំឡុងពេលនីតិវិធីសវនាការ គឺមានតិចតួចណាស់។ ដូច្នេះ ក្រោយពីមានការវិភាគទៅលើសារណាបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២ បង្ហាញច្បាស់ថា អង្គជំនុំជម្រះតុលាការកំពូលឥឡូវនេះគឺត្រូវលះបង់ពេលវេលារបស់ខ្លួនប្រមាណ៥០% ដើម្បីពិនិត្យពិច័យទៅលើបញ្ហាទាំងឡាយ ដែលអាចត្រូវបានដោះស្រាយបានមុន ដូចនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ឬសាលាក្តីមិនអចិន្ត្រៃយ៍។

៤២ ដោយពិចារណាទៅលើកត្តាទាំងនេះ និង បទពិសោធន៍ដែលពាក់ព័ន្ធសម្រាប់រឿងក្តីដែលមាន ទំហំ និងភាពស្មុគស្មាញប្រហាក់ប្រហែលគ្នា ការប៉ាន់ស្មានដ៏ត្រឹមត្រូវបំផុតដែលអាចផ្តល់បាននៅពេលនេះគឺថា ដំណើរការបណ្តឹងសាទុក្ខអាចនឹងត្រូវបញ្ចប់យ៉ាងឆាប់បំផុតគឺនៅចុងត្រីមាសទីពីរក្នុងឆ្នាំ២០១៦។ មានហេតុផលចាំបាច់ក្នុងការកែប្រែពេលវេលាសម្រាប់បញ្ចប់ដំណើរការបណ្តឹងសាទុក្ខក្នុងរយៈពេលបីខែនោះ។ ទីមួយ ភ័ស្តុតាងបន្ថែមដែលត្រូវបានដាក់នោះ បានធ្វើឲ្យកិច្ចដំណើរការនីតិវិធីនេះកាន់តែមានភាពស្មុគស្មាញ ដែលធ្វើឲ្យមានការឆ្លើយតបមួយចំនួន ក្នុងនោះរួមទាំងការធ្វើការស៊ើបអង្កេតបន្ថែមរបស់អង្គជំនុំជម្រះតុលាការកំពូលដែលពុំទាន់បានបញ្ចប់នៅឡើយ និងការបើកសវនាការពិនិត្យភ័ស្តុតាងផ្សេងទៀត។ យើងគួរលើកឡើងផងដែរថា សំណើទី ៦ សុំភ័ស្តុតាងបន្ថែម ដែលបានដាក់កាលពីពាក់កណ្តាលខែកញ្ញា ឆ្នាំ២០១៥ មានទំហំធំធេង និងបានលើកបញ្ហាអង្គច្បាប់ និងអង្គហេតុយ៉ាងចាក់ស្រេះជាច្រើន។ ដូច្នេះ សូមរម្លឹកថា នៅពេលដោះស្រាយបញ្ហាភ័ស្តុតាងបន្ថែមនៅក្នុងដំណាក់កាលបណ្តឹងសាទុក្ខ សំអាងហេតុរបស់អង្គជំនុំជម្រះត្រូវតែយកមកពិនិត្យមើលឡើងវិញ

ដោយពិនិត្យទៅលើភស្តុតាងបន្ថែម និងភស្តុតាងទាំងអស់ដែលអង្គជំនុំជម្រះបានសំអាង។ ចំណុចទីពីរ ដោយសារដំណាក់កាលនៃការដាក់សារណាលើអង្គសេចក្តីនៃបណ្តឹងសាទុក្ខបានបញ្ចប់ហើយនោះ នៅពេលនេះ អង្គជំនុំជម្រះតុលាការកំពូលអាចវាយតម្លៃស៊ីជម្រៅពេញលេញលើបណ្តឹងសាទុក្ខដែលកំពុងរង់ចាំសេចក្តីសម្រេចនេះ ដែលមានលក្ខណៈកាន់តែស្មុគស្មាញខ្លាំងជាងការរំពឹងទុកពីដើមដំបូង។ លើសពីនេះ យើងត្រូវកត់សម្គាល់ផងដែរថា សារណាផ្ទាល់មាត់របស់ភាគីនាពេលខាងមុខអាចមានផលប៉ះពាល់លើការវាយតម្លៃនេះ។ ចំណុចទីបី និងដូចមាននៅក្នុងរាយការណ៍នាពេលមុនរួចហើយ អង្គជំនុំជម្រះតុលាការកំពូលធ្លាប់ជួបបញ្ហានៃការបកប្រែឯកសារ។ ទោះបីជាកត្តានេះមានផលប៉ះពាល់លើពេលវេលារួមក៏ដោយ យើងសង្ឃឹមថា ការចាត់ចែងនាពេលថ្មីៗនេះលើបញ្ហានៃការបកប្រែសម្រាប់អង្គជំនុំជម្រះតុលាការកំពូល នឹងអាចជៀសវាងការកើតមានបញ្ហានេះទៀត។

៤៣ ពាក់ព័ន្ធនឹងវិធានការបន្ទាប់ ក្នុងរយៈពេលប៉ុន្មានខែខាងមុខ នឹងមានការពិនិត្យមើលឯកសារទាំងអស់ដែលបានដាក់ ការធ្វើការសម្រេចលើសំណើសុំនានាដែលស្នើសុំភស្តុតាងបន្ថែម ក្រោយពេលរៀបចំ និងការធ្វើសវនាការលើបណ្តឹងសាទុក្ខដែលគ្រោងនឹងធ្វើឡើងនៅត្រឹមបំណាចឆ្នាំ២០១៥។ បន្ទាប់មក អង្គជំនុំជម្រះតុលាការកំពូលនឹងបញ្ចប់ការពិភាក្សាសម្រេច និងរៀបចំចេញសាលដីកាក្នុងសំណុំរឿង ០០២/០១។

## ខ. <u>សំណុំរឿង០០២/០២</u>

៤៤ សម្រាប់សំណុំរឿង០០២/០២ ដោយផ្អែកលើការព្យាករណ៍បច្ចុប្បន្នរបស់អង្គជំនុំជម្រះសាលាដំបូងដែលថាការជំនុំជម្រះដំណាក់កាលទីពីរទំនងជានឹងមានលក្ខណៈស្មុគស្មាញ និងត្រូវការពេលវេលាច្រើនដូច ជាការជំនុំជម្រះដំណាក់កាលទីមួយនោះ អង្គជំនុំជម្រះតុលាការកំពូលក៏ព្យាករណ៍ស្រដៀងគ្នានេះដែរនៅពេលនេះដែលថាបណ្តឹងសាទុក្ខ(ទាំងឡាយ)ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះក្នុងសំណុំរឿង០០២/០២នឹងមានលក្ខណៈស្មុគស្មាញនិងត្រូវការពេលវេលាច្រើន ដូចគ្នានឹងបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២/០១ និង កត្តានានា ដូចជាសំណើសុំ ពន្យារពេលក្នុងការដាក់សារណា ឬញត្តិដើម្បីស្នើដាក់ជូនភស្តុតាងបន្ថែម អាចប៉ះពាល់ដល់រយៈពេលនៃដំណើរការនីតិវិធីបណ្តឹងសាទុក្ខ។ ទំហំការងារបែបនេះនឹងត្រូវការគិតបញ្ចូលទៅក្នុងការរៀបចំផែនការក្រោយពេលមានការដាក់បណ្តឹងសាទុក្ខ ។

01739865

៤៥ ជាងនេះទៅទៀត បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង០០២/០២ ត្រូវតែសម្រេចក្នុងរយៈពេលបីខែជាកំណត់។ ផ្អែកលើបទពិសោធន៍ពីសំណុំរឿង០០២/០១ គិតជាមធ្យម រំពឹងថាមានបណ្តឹងសាទុក្ខភ្លាមៗចំនួនមួយផងដែរក្នុងមួយខែក្នុងរយៈពេលមាននីតិវិធីសវនាការក្នុងសំណុំរឿង០០២/០២។ ប្រការនេះអាចធ្វើឲ្យមានតម្រូវការធនធានរបស់អង្គជំនុំជម្រះតុលាការកំពូលកាន់តែធំឡើង ហើយ ប៉ះពាល់ដល់តារាងកំណត់ពេលវេលាសម្រាប់ការចេញសាលដីកា លើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១។

## VI. សេចក្តីសន្និដ្ឋាន

៤៦ សម្រាប់ឆ្នាំ ២០១៥ កិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២/០១ និង នីតិវិធីជំនុំជម្រះក្តីក្នុងសំណុំរឿង០០២/០២ នឹងបន្តស្របគ្នារហូតពេញមួយឆ្នាំ។ សម្រាប់សំណុំរឿង ០០២/០១ រំពឹងថានឹងសម្រេចបាននូវគ្រោងការ ១ ថែមទៀត គឺ ការបញ្ចប់សវនាការលើបណ្តឹងសាទុក្ខ។ មានការរំពឹង ថានឹងសម្រេចបាននូវគ្រោង ការថ្មីចំនួន១ពោលគឺទាក់ទិននឹង សំណុំរឿង០០៣ និង ០០៤ ពោលគឺ សេចក្តីជូនដំណឹងអំពីការបញ្ចប់ កិច្ចស៊ើបសួរ ក្នុងសំណុំរឿង០០៣។ ជាងនេះទៀត ប្រសិនបើសំណុំ រឿង០០៤ ត្រូវបានបំបែក មានការ រំពឹងថាសេចក្តីជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរក្នុងសំណុំរឿង ចំនួន២ ក្នុងចំណោម សំណុំរឿងចំនួន៣ដែលបានបំបែក ក៏អាចនឹងត្រូវចេញនៅចុងឆ្នាំ២០១៥នេះផង ដែរ។

៤៧ សម្រាប់ឆ្នាំ២០១៦ គេរំពឹងថា គ្រោងការចំនួន៣នឹងត្រូវសម្រេចបានក្នុងសំណុំរឿង០០២/០១ និង ០០២/០២៖ (i) ការចេញសាលក្រមក្នុងសំណុំរឿង០០២/០១ (ii) ការបញ្ចប់សវនាការលើអង្គសេចក្តី/ភស្តុតាងក្នុងសំណុំរឿង០០២/០២ និង(iii) ការចេញសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលក្នុងសំណុំរឿង០០២/០២។ ចំពោះសំណុំរឿង០០៣ និង ០០៤ មានការរំពឹងថា នឹងសម្រេចបានគ្រោងការចំនួន៣៖ (i)ការចេញដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៣ ជាមួយនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតថាតើត្រូវបញ្ជូនសំណុំ រឿងទៅជំនុំជម្រះ ឬ បញ្ចប់កិច្ចនីតិវិធីតែម្តង។ (ii) សេចក្តីជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៤ និង (iii)ការចេញដីកាដំណោះស្រាយមួយ(ច្រើន)ក្នុង សំណុំរឿង០០៤ ជាមួយនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតថាតើត្រូវបញ្ជូនសំណុំរឿង ទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធី។

៤៨ សម្រាប់ឆ្នាំ២០១៧ មានការរំពឹងថានឹងសម្រេចបាននូវគ្រោងការចំនួន២ក្នុងសំណុំរឿង០០២/០២ ពោលគឺ៖ (i) ការចេញសាលក្រមលើសំណុំរឿង០០២/០២ (ii) កាលបរិច្ឆេទចុងក្រោយក្នុងការដាក់បណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២។ ក្នុងសំណុំរឿង០០៣ និង ០០៤ រំពឹងថានឹង សម្រេចបានគ្រោងការសំខាន់ចំនួនពីរបន្ថែមទៀតគឺ (i) ការសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង០០៣ និង (ii) ការសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង០០៤ ជាមួយនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះថាតើត្រូវបញ្ជូនសំណុំរឿងទាំងនេះទៅជំនុំជម្រះឬបញ្ចប់កិច្ចនីតិវិធី។ ក្នុងករណីដែលសំណុំរឿងណាមួយ ឬសំណុំរឿងទាំងពីរ ត្រូវបានបញ្ជូនទៅជំនុំជម្រះទាំងមូល ឬដោយផ្នែក ការព្យាករណ៍ទុកនូវតារាងកំណត់ពេលវេលាក្នុងសំណុំរឿងទាំងនេះគឺអាចយកមកវាយតម្លៃបាន។

៤៩ ក្នុងអំឡុងឆ្នាំ ២០១៨ អង្គជំនុំជម្រះតុលាការកំពូលនឹងជាប់រវល់ធ្វើសវនាការបណ្តឹងសាទុក្ខ និងការពិភាក្សាសម្រេច ក្នុងករណីដែលមានបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង។

៥០ សម្រាប់ឆ្នាំ២០១៩ មានការរំពឹងថានឹងសម្រេចបាននូវគ្រោងការចំនួនមួយ គឺ ៖ (i) ការចេញសាលដីកាលើសំណុំរឿង០០២/០២។

៥១ ការស្មានទុកនូវគ្រោងការនានាដែលរៀបរាប់ខាងលើនេះ មានសង្ខេបជូនក្នុងតារាងដែលភ្ជាប់ជូនជាមួយនឹងផែនការនេះស្រាប់។

# តារាងកំណត់ពេលវេលាតាមការគ្រោងទុក ដែលរួមមានគ្រោងការសំខាន់ៗ




(ក) ការបញ្ចប់សវនាការលើបណ្ដឹងសាទុក្ខ

(ខ) សាលដីកា




(គ) ការបញ្ចប់សវនាការលើអង្គសេចក្ដី

(ឃ) សេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល

(ង) សាលក្រម

(ច) កាលបរិច្ឆេទកំណត់សម្រាប់បណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រម

(ឆ) សាលដីកា




(ជ) ការជូនដំណឹងអំពីការបញ្ចប់ការស៊ើបអង្កេត
(ឈ) ដីកាដំណោះស្រាយ កសចស
(ញ) សេចក្ដីសម្រេចរបស់ អបជ ទៅលើដីកាដំណោះស្រាយ







(ដ) ការជូនដំណឹងអំពីការបញ្ចប់ការស៊ើបអង្កេត។ ពេលវេលាកំណត់អាស្រ័យទៅលើថាតើ សំណុំរឿងនឹងត្រូវបានបំបែកឬទេ។

(ឋ) ដីកាដំណោះស្រាយ កសចស។ ពេលវេលាកំណត់អាស្រ័យទៅលើថាតើ សំណុំរឿងនឹងត្រូវបានបំបែកឬទេ។

(ឌ) សេចក្ដីសម្រេចរបស់ អបជ ទៅលើដីកាដំណោះស្រាយ